# ជំហានទី៣

**ធ្វើការសម្រេចចិត្ត! អនុញ្ញាតឲ្យព្រះធ្វើជាអ្នកកាន់ចង្កូតជីវិតរបស់យើង**
**ឲ្យស្ថិតនៅក្រោមការថែរក្សារបស់ព្រះនៅពេលដែលយើងបានយល់ពីព្រះហឫទ័យព្រះអង្គ**

**ជំហានទី៣**នេះ ប្រៀបដូចជាយើងឃើញទ្វារមួយដែលចាក់សោលេចមកចំពោះមុខយើង តែអ្វីដែលយើងត្រូវការគឺ កូនសោទ្វារ ហើយឆន្ទៈក្នុងការបើកវា។ យើងអាចប្រៀបប្រដូចកូនសោទៅជាឆន្ទៈរបស់យើង។ ពេលដែលយើងសម្រេចចិត្តបើកទ្វារនោះ យើងនឹងឃើញគោលដៅ និងទិសដៅមួយ។ ទិសដៅនោះ 'គឺការស្វែងរកជំនឿមួយដែលអាចជួយអ្នកឲ្យសម្រេចបាន'។

*ជំហានទី១: យើងត្រូវទទួលស្គាល់ខ្លួនឯងថា យើងគ្មានអំណាចលើសារជាតិស្រវឹងឡើយ ហើយយើងមិនអាចគ្រប់គ្រងជីវិតយើងបានឡើយ។*

*ជំហានទី២: យើងត្រូវជឿថាមានអំណាចមួយដែលខ្លាំងជាងយើង! ហើយអាចជួយឲ្យយើងអាចរួចផុតពីភាពឆ្កួតវង្វេង។ ដូចនេះជំហានទាំងពីរខាងលើគ្រាន់តែទាមទារឲ្យអ្នកសារភាពកំហុស និងទទួលស្គាល់ការពិតដោយមិនចាំបាច់មានសកម្មភាពណាមួយទៀតទេ។*

***ជំហានទី៣:*** គឺទាមទារសកម្មភាព ឯសកម្មភាពនោះគឺត្រូវមានជំនឿលើអំណាចដ៏ខ្ពស់បំផុត ទោះបីជាយើងកំពុងចូលរួមជាមួយក្រុមអេអេក៏ដោយ។ ជំនឿតែមួយមុខមិនគ្រប់គ្រាន់ក្នុងការដែលជួយយើងឲ្យសម្រេចគោលបំណងយើងទេ ហើយក៏ជារនាំងដែលខណ្ឌចែកយើងចេញពីជំនួយរបស់ព្រះផងដែរ ប៉ុន្តែបន្ថែមលើជំនឿដែលយើងមាននេះ យើងត្រូវអនុញ្ញាតឲ្យអំណាចដ៏ខ្ពស់បំផុតគង់ក្នុងជីវិតយើង ហើយអនុញ្ញាតឲ្យទ្រង់ជួយយើង។ ជំហានទី៣ គឺជំហានមួយដែលមានការទាក់ទងទៅនឹងកម្មវិធី អេអេទាំងស្រុង ព្រោះវាជាជំហានសំខាន់បំផុតដែលជួយយើងក្នុងការសម្រេចឆន្ទៈ និងអនុញ្ញាតឲ្យព្រះធ្វើជាអ្នកកាន់ចង្កូតជីវិតរបស់យើង ដោយស្ថិតនៅក្រោមការថែរក្សារបស់ព្រះ នៅពេលដែលយើងយល់ពីព្រះហឫទ័យព្រះអង្គ។ ចំពោះអ្នកដែលមិនមានជំនឿ ឬសាសនា ជំហ៊ាននេះគឺលំបាកណាស់សម្រាប់ពួកគេ ព្រោះមនុស្សបែបមិនមានជំនឿ ឬសាសនា គឺគេពឹងខ្លួនឯង ហើយគេគិតថាគេអាចដោះស្រាយបញ្ហាដោយខ្លួនឯងបាន ម្យ៉ាងទៀតវាជាការលំបាកណាស់ក្នុងការដែលគេឲ្យជីវិតរបស់គេស្ថិតនៅក្រោមការមើលថែរបស់ព្រះ ព្រោះគេមិនជឿថាមានព្រះនោះទេ។ ពួកអេអេខ្ញុំក៏ដូចអ្នកទាំងនោះដែរ ព្រោះពេលចូលរួមជាមួយកម្មវិធីអេអេដំបូង ពួកយើងមានចម្ងល់នៅក្នុងចិត្តជាច្រើន ប៉ុន្តែពួកយើងព្យាយាមធ្វើ និងស្វែង

យល់ពីវា ឥឡូវនេះយើងយល់ច្បាស់ណាស់ថា នេះពិតជាអាចជួយយើងពិតប្រាកដមែន។ ដំបូងយើងត្រូវមានការចាប់ផ្តើមៈ ប្រៀបដូចជាកូនសោមួយដែលយើងមានចិត្តចង់យកទៅចាក់ បន្ទាប់មក យើងត្រូវចាប់យកកូនសោ ហើយយកវាទៅចាក់។ ឥឡូវយើងគិតរបៀបនេះវិញ! គ្រប់គ្នាដែលចូលរួមជាមួយកម្មវិធីអេអេ បានឆ្លងកាត់ជំហានទី១ និងទី២រួចហើយ នេះមានន័យថាគេមានកាចាប់ផ្តើមរួចហើយ ដោយគេព្រមឲ្យក្រុមអេអេ ជួយថែរក្សាការពារ និងណែនាំ អំពីការញៀនគ្រឿងស្រវឹង នេះបញ្ជាក់ពីឆន្ទៈមួយក្នុងការចង់ឈប់ផឹកគ្រឿងស្រវឹង។ ដូចនេះជំហានទី៣ គឺជាជំហានមួយដែលអ្នកញៀនគ្រឿងស្រវឹង ត្រូវតែពឹងអាងលើអំណាចដ៏ខ្ពស់បំផុត ដើម្បីសម្រេចបាននូវឆន្ទៈដែលយើងមានចំពោះភាពឈប់ញៀន។

ដូចគ្នាដែរគ្រប់គ្នាដែលបានចូលរួមជាមួយកម្មវិធីអេអេ សម្រាប់ផ្តាច់គ្រឿងស្រវឹង ពួកគេបាន ចាប់ផ្តើមជំហានទី៣រួចហើយ។ ពួកគេបានបើកទ្វារចិត្តដើម្បីទទួលយកអ្វីដែលអាចជួយពួក គេឲ្យសម្រេចតាមឆន្ទៈរបស់ពួកគេ ជាជាងការដែលពឹងលើកំលាំង គំនិត ប្រាជ្ញា និងទស្សនវិស័យរបស់ខ្លួនគេ។ ពួកគេដឹងហើយថាផ្លូវដែលពួកគេបានដើរពីមុនមិនមានជោគជ័យនោះទេ ពួកគេមិនអាចពឹងលើកំលាំងគំនិត ប្រាជ្ញា និងទស្សនវិស័យបស់ខ្លួនគេក្នុងការបញ្ឈប់ភាពញៀនរបស់ពួកគេពុំបានឡើយ។ ប្រហែលមានអ្នកខ្លះនិយាយថា 'អ្វីដែលពួកគេចង់ធ្វើជាមួយភាពញៀនស្រានោះគឺ ត្រូវផ្លាស់ប្តូរការគិត ឆន្ទៈរបស់គេទៅឯកម្មវិធីអេអេ ដោយពឹងផ្អែកលើកម្មវិធីអេអេទាំងស្រុង' ប៉ុន្តែផ្នែកឯទៀតដែលខ្ញុំមាន តើខ្ញុំគិតយ៉ាងម៉េចទៅ តើខ្ញុំអាចរក្សាភាពម្ចាស់ការលើខ្លួនឯងបានដែរឬទេ? ចុះបើខ្ញុំផ្ទុកដាក់ផ្នែកផ្សេងៗទៀតទៅឯអ្នកដទៃ តើនឹងមានរឿងអ្វីកើតដល់ខ្ញុំទៅ? ឬក៏ខ្ញុំនឹងក្លាយទៅជាមនុស្សយន្ត? ប៉ុន្តែបើខ្ញុំពឹងផ្អែកលើកម្មវិធីអេអេ និងអំណាចដ៏ខ្ពស់បំផុតខ្លាំងប៉ុណ្ណា ខ្ញុំនឹងមានសេរីភាព និងភាពម្ចាស់ការលើ ខ្លួនឯងកាន់តែខ្លាំង។ ខ្ញុំចង់បានសេរីភាពក្នុងការធ្វើអ្វីៗគ្រប់យ៉ាង ហើយខ្ញុំក៏ចង់មានភាពម្ចាស់ការ និង ភាពក្លាហានចំពោះអ្វីៗដែលនឹងកើតមកលើរូបខ្ញុំផងដែរ។

***ឧបមាថាៈ*** យើងទាំងអស់គ្នាប្រើប្រាស់អគ្គីសនី ហើយក្តីសង្ឃឹមរបស់យើងគឺមិនជួបប្រទះការដាច់ភ្លើង ដូចនេះយើងពឹងផ្អែកលើអគ្គីសនីទាំងស្រុង ការពឹងផ្អែកលើអគ្គីសនីរបស់យើងធ្វើឲ្យយើងមានសេរីភាពច្រើន និងភាពម្ចាស់ការកាន់តែច្រើនឡើងថែមទៀត។ យើងអាចចំអិនអាហារដោយមិនប្រើធ្យូង ចំណាយពេលយូរ អស់កំលាំង ហើយមិនចាំបាច់ចាំយូរនោះទេ។ យើងមានភាពសុខស្រួលព្រោះយើងអាចប្រើប្រាស់កង្ហារ ម៉ាស៊ីនត្រជាក់ យើងអាចរក្សាម្ហូបអាហារយើងបានយូរ មានអនាម័យ ចំណែកពេលយប់យើងអាចធ្វើការដល់ពេលយប់បានយូរ និងធ្វើអ្វីផ្សេងៗយ៉ាងច្រើនសប្បាយរីករាយ។ ដូច្នេះបើអគ្គីសនីដាច់ ឬមិនមានអគ្គីសនីនោះយើងមិនមានសេរីភាពគ្រប់គ្រាន់ទេ។ អ្នកញៀនដូចយើងចូលចិត្តសម្រេចចិត្ត និងធ្វើអ្វីតាមតាមអ្វីដែលយើងបានគិត វាជាឯកសិទ្ធមួយនៅក្នុងដៃរបស់អ្នក ដូចនេះយើងអាចពិចារណាអំពីគុណសម្បត្តិ និងគុណវិបត្តិនៃបញ្ហា។ យើងអាចស្តាប់ការទូន្មានរបស់អ្នកដទៃ ប៉ុន្តែយើងជឿថារាល់ការសម្រេចចិត្តនៅក្នុងជីវិតយើង គឺជាការសម្រេចចិត្តផ្ទាល់ខ្លួន ហើយយើងតែម្នាក់ដែលបាន

បង្កើតវាមក។ គ្មានអ្នកណាអាចបង្អាក់សេរីភាពនៃការសម្រេចចិត្ត ការគិតត្រិះរិះពិចារណារ និងទង្វើរបស់យើងបានទេ។ អ្នកញៀនគ្រឿងស្រវឹងគេយល់ថាគ្មាននណាម្នាក់ដែលគេអាចទុកចិត្តបានឡើយ ហើយគេក៏គិតថាខ្លួនគេជាមនុស្សពិសេស។

យើងគិតថាយើងមានអំណាច បញ្ញា ស្មារតីគ្រប់គ្រាន់ក្នុងការគ្រប់ គ្រងជីវិតខាងក្នុងរបស់យើងដើម្បីឲ្យ ជីវិតយើងទទួលបានជោគជ័យនៅក្នុងពិភពលោកនេះ។ នេះគឺជាទ្រឹស្តីបទមួយក្នុងទ្រឹស្តីបទជាច្រើនទៀត ប៉ុន្តែអ្នកញៀនគ្រឿងស្រវឹងទាំងអស់គួរតែធ្វើបែបនេះវិញ! ចូរទៅឆ្លុះបញ្ចាំងតើទ្រឹស្តីបទខាងលើពិតជាជួយជីវិតខ្ញុំពិតប្រាកដ ឬគ្រាន់តែជាទ្រឹស្តីបទដែលលាក់បាំងការពិតរបស់ខ្ញុំ។ ព្យាយាមឆ្លុះកញ្ចក់ព្រោះជាធម្មតាអ្នកញៀនគ្រឿងស្រវឹងគេគិតថារូបរាងរបស់គេអាក្រក់ណាស់។ សូមមើលទៅក្នុងសង្គមយើងបច្ចុប្បន្នវិញ យើងឃើញថាគេរស់នៅដោយពឹងផ្អែកលើខ្លួនគេផ្ទាល់ ដោយប្រើសេរីភាពរបស់គេ ប៉ុន្តែយើងក៏ឃើញដែរថាគេកំពុងរស់នៅលាយឡំជាមួយភាពភ័យខ្លាច កំហឹង និង ភាពច្របូកច្របល់ដែលកើតមាននៅក្នុងសង្គមបច្ចុប្បន្ន ដែលបណ្តាលមកពីការប្រឆាំងគ្នា។ អ្នកខ្លះប្រកាន់យកភាពត្រឹមត្រូវរបស់ខ្លួន និងចោទប្រកាន់អ្នកដទៃថាខុស។ ក្រុមនីមួយៗគេទាមទារឲ្យក្រុមផ្សេងដទៃៗគោរពប្រត្តិបត្តិដល់ក្រុមរបស់ខ្លួន។

ការនេះវាកើតឡើងចំពោះបុគ្គល ម្នាក់ៗ ក្រុមគ្រួសារ ស្ថាប័នការងារ និងស្ថាប័នសាសនាផងដែរ។ ការប្រើសិទ្ធិរបស់យើងដោយពឹងផ្អែកលើឆន្ទៈ ប្រាជ្ញារបស់យើងផ្ទាល់គឺនាំយើងទៅរកភាពខ្វះខាតសន្តិភាព និងភាពសុខសាន្ត។

ទស្សនវិស័យចំពោះការពឹងផ្អែកលើខ្លួនឯងវាមិនមែនជាការល្អនោះទេ តែវានាំយើងទៅរកភាពហិនវិនាសទៅវិញទេ។ ***អ្នកញៀនគ្រឿងស្រវឹងដឹងច្បាស់ហើយថា ឆន្ទៈរបស់គេបាននាំគេឲ្យធ្វើអ្វីខ្លះនៅពេលដែលគេឆ្លុះកញ្ចក់ ហើយអ្នកខ្លះទៀតកំពុងតែស្វែងរកភាពល្អប្រសើរសម្រាប់ជីវិតរស់នៅរបស់គេ។***

វិបត្តិដែលដែលអ្នកញៀនស្រាបានជំរុញអ្នកញៀនស្រាមកកាន់អេអេ ព្រោះតែគេដឹងថាគ្មានផ្លូវណាទៀតសោះដែលអាចជួយគេបាន។ អ្នកញៀនស្រាអនាមិកមើលឃើញថា ផ្លូវដែលគាត់បានដើរមិនបានជួយអ្វីសោះដល់គាត់ ពួកគេបានសារភាពអំពីការបរាជ័យដែលគេមាន។ ជំនឿតិចតួចប៉ុណ្ណោះ ដែលពួកគេមានសម្រាប់ធ្វើការសម្រេចចិត្ត អនុញ្ញាតឲ្យអំណាចដ៏ខ្ពស់បំផុតជាអ្នកកាន់ចង្កូតជីវិតរបស់គេហើយឲ្យជីវិតរបស់គេស្ថិតក្នុងការថែរក្សារបស់អំណាចដ៏ខ្ពស់នោះ។

កាលណាយើងនិយាយអំពីការពឹងផ្អែកលើអំណាចដ៏អស្ចារ្យដ៏ខ្ពស់បំផុត នោះយើងដឹងហើយថាមានមធ្យោបាយជាច្រើនក្នុងការពឹងផ្អែកលើអំណាចដ៏ខ្ពស់បំផុតប៉ុន្តែការពឹងពាក់ មួយជំនួនមិនមែនជា

មធ្យោបាយដែលល្អទេ។ ឧទាហរណ៍ថា: ក្មេងប្រុសជំទង់ម្នាក់បានពឹងផ្អែកទាំង ស្រុងទៅលើឪពុក ម្ដាយរបស់ខ្លួន ស្វាមីពឹងផ្អែកទៅលើភរិយាហួសហេតុពេក ឬនរណាម្នាក់នៅកន្លែងធ្វើការ តែងតែពឹងផ្អែកលើបុគ្គលិកធ្វើការជាមួយគ្នាជ្រុលពេក។ ការពឹងផ្អែកចំពោះនរណាម្នាក់ខ្លាំងពេកនោះ គឺធ្វើឲ្យអ្នកដែលពាក់ព័ន្ធជាមួយយើងមិនអាចមានសេចក្ដីសុខឡើយ។ ចំពោះអ្វីដែលយើងបានឃើញ កន្លងមកនៅក្នុងកម្មវិធីអេអេ គឺការពឹងផ្អែកលើក្រុមរបស់អេអេ ហើយនឹងពឹងទៅលើអំណាចដ៏ខ្ពស់បំផុត នោះវាមិនអាក្រក់ដូចដែលយើងបានពឹងផ្អែកទៅលើខ្លួនយើងផ្ទាល់ ឬពឹងលើអ្នកដទៃនោះទេ។

ក្រុមអេអេបានកើតឡើងមុនសង្គ្រាមលោកលើកទី២ ប្រមាណ២ ឬ៣ឆ្នាំ កំឡុងឆ្នាំ១៩៣៧ នៅសហរដ្ឋអាមេរិក។ ក្រុមអេអេមានការងឿងឆ្ងល់ថា តើមានអ្វីកើតឡើងចំពោះអ្នកដែលបានចូលរួមជាមួយកម្មវិធីអេអេហើយ តែត្រូវប្រទេសបញ្ជូនទៅធ្វើសង្គ្រាម តើពួកគេអាចទប់ទល់ជាមួយនឹងសម្ពាធដែលមាននៅក្នុងសង្គ្រាមបានដែរឬទេ? ព្រោះថានៅក្នុងសង្គ្រាមជាកន្លែងដែលមានសម្ពាធច្រើន និងខ្លាំងជាងគេ។ ប៉ុន្តែចម្លល់នោះបានលេចមកឲ្យឃើញ តាមរយៈអ្នកទាំងនោះពេលដែលគេត្រឡប់មកវិញ។ ស្ថិតិបានបញ្ជាក់ថាអ្នកដែលបានបញ្ជូនទៅធ្វើសង្គ្រាម ហើយមានសម្ពាធច្រើននោះបែរជាមិនត្រឡប់ទៅ សេពគ្រឿងស្រវឹង ដូចអ្នកដែលនៅផ្ទះដែលមិនបានចូលទៅបម្រើកងទ័ព។ ពួកគេទទួលបានជោគជ័យ ដោយសារតែគេរៀនពឹងផ្អែកលើអំណាចដ៏ខ្ពស់បំផុតក្នុងគ្រប់ស្ថានភាពទាំងអស់ ដោយមិនមែនគ្រាន់តែផ្ដាច់ខ្លួនចេញពីស្រានោះទេ។ ពួកគេបានរកឃើញនូវធនធាននៃភាពខ្លាំងរបស់ពួកគេ គឺនៅក្នុងអំណាចដ៏ខ្ពស់ដែលពួកគេបានពឹង ម្យ៉ាងទៀតពួកគេអាចអនុវត្តបានគ្រប់ស្ថានភាព និងគ្រប់កាលៈទេសៈ។

ដូច្នេះ! តើអ្នកដែលមានបំណងចង់ប្រគល់ជីវិតរបស់ពួកគេទៅទុកដាក់លើអំណាចខ្ពស់នោះយ៉ាងដូចម្ដេចទៅ? វាមិនលំបាកនោះទេ គឺចាប់ផ្ដើមជាមួយក្រុមអេអេ ហើយទុកចិត្តក្រុមអេអេចំពោះបញ្ហាញៀនស្រារបស់គេ។ អ្នកនឹងឃើញលទ្ធផលតាមរយៈកម្មវិធីអេអេ។ ប្រសិនបើនរណាម្នាក់បានចូលរួមនៅក្នុងកម្មវិធីនេះក្នុងរយៈពេលខ្លះ ហើយបានឆ្លងកាត់ជំហានទី១ និងជំហានទី២នោះគេនឹងឃើញថាគេពិតជាមានបញ្ហាជាច្រើនផ្សេងទៀត ក្រៅអំពីបញ្ហាញៀនស្រា ហើយបញ្ហាទាំងនោះវានឹងមិនអាចដោះស្រាយបានដោយឆន្ទៈ ការលើកទឹកចិត្ត និងការប្ដេជ្ញាចិត្តរបស់ខ្លួនឯងផ្ទាល់បានទេ។ សមាជិកថ្មីដែលទើបនឹងចូលរួមជាមួយក្រុមអេអ អាចមានអារម្មណ៍ថា គេនឹងមិនអាចសម្រេចនូវអ្វីដែលគេចង់បាននោះទេ តែនេះគឺគ្រាន់តែជាការគំរាមគំហែងដល់ការឈានទៅកាន់ភាពជ្រះស្រឡះចេញពីភាពញៀនរបស់គេ ជាពិសេសនៅពេលដែលគេគិតអំពីអតីតកាលរបស់គេ ការរស់នៅ និងទង្វើដែលខុសឆ្គងចំពោះមនុស្សដែលគេស្រឡាញ់ដូចជាប្រពន្ធ កូន គ្រួសារ...។ គេនៅតែមានភាពល្ងីងល្ងើរចត់ មានការឈឺចាប់ខ្លាំង មានកំហឹងពោរពេញដោយភាពស្អប់ខ្ពើម ចំពោះអ្នកដែលគេគិតថាអ្នកទាំងនោះបានធ្វើអ្វីមិនល្អមកលើគេ (ទោះបីជាធាតុពិតអ្នកទាំងនោះគេមិនបានធ្វើអ្វីដាក់គាត់ក៏ដោយ)។ គេពិតជាបារម្ភអំពីសុវត្ថិភាពនៃហិរញ្ញវត្ថុរបស់គេ សុវត្ថិភាពរបស់គេនៅក្នុងថ្ងៃអនាគត ហើយគេមានភាពភ័យខ្លាច និងបារម្ភចំពោះអ្វីដែលគាត់បានធ្វើ

ពីមុន។ វាដូចជាគាត់បានបិទផ្លូវទាំងអស់របស់ខ្លួនអីចឹង ដោយព្រោះតែគាត់បានពុល ហើយបានបំផ្លាញទំនាក់ទំនងដ៏ល្អទាំងប៉ុន្មានពីមុននោះ។ តើពួកគេអាចធ្វើយ៉ាងដូចម្តេច ដើម្បីដោះស្រាយនូវបញ្ហាក្នុងគ្រួសារ បំណងអាពាហ៍ពិពាហ៍ ឬក៏ទំនាក់ទំនងដ៏ល្អរបស់ពួកគេ? តើគេនឹងត្រូវដោះស្រាយយ៉ាងណា? ដូចនេះមានតែពឹងផ្អែកលើនរណាម្នាក់ ឬក៏អ្វីមួយ។

អ្នកញៀនស្រាដែលបានចូលរួមនៅថ្ងៃដំបូង នៃការផ្តាច់ខ្លួនចេញពីភាពស្រវឹងស្រានៅក្នុងក្រុម អេអេនោះ ឥឡូវនេះពួកគាត់បានបញ្ឈប់ការផឹកស្រានោះហើយ ឥឡូវយើងអាចមើលឃើញថា រាល់បញ្ហាទាំងអស់របស់ពួកគាត់នោះត្រូវបានដោះស្រាយ។ ដៃគូរបស់ អេអេ ឬអ្នកដែលបានផ្តល់ឱវាទដល់ អេអេ បានធ្វើគេដឹងថា ទោះបីជាពួកគេបានបញ្ឈប់ការផឹកស្រាក៏ដោយ ក៏គេនៅតែមិនអាចគ្រប់គ្រងជីវិតរបស់គេបានដែរ។ កម្មវិធីផ្តាច់ពីស្រាថ្មី ការចូលរួមរាល់ការប្រជុំរបស់អេអេ និងការដែលយើងកំពុង តែធ្វើការលើជំហានទាំងនោះ ទោះយ៉ាងណាក៏ដោយក៏មិនទាន់គ្រប់គ្រាន់នៅឡើយ ក្នុងការដែលយើងអាចបង្កើតភាពរីករាយ អ្វីដែលមានប្រយោជន៍សម្រាប់ជីវិត និងជីវិតដែលមានភាពប្រក្រតីនៅឡើយទេ។ អ្នកញៀនត្រូវតែបន្តទៅជំហានផ្សេងៗទៀតក្នុងគោលបំណង ដើម្បីឲ្យមានប្រសិទ្ធិភាពលើបញ្ហា និងភាពខ្វះខាតនូវចរិកលក្ខណៈរបស់គេ។

សម្រាប់ជំហានតទៅទៀតនោះគឺត្រូវទាមទារឲ្យមានសកម្មភាពច្រើន ដោយមានការប្តេជ្ញាចិត្ត ហើយក៏មានភាពលំបាកផងដែរ។ ប៉ុន្តែឥឡូវនេះ គ្រាន់តែធ្វើការអនុវត្តន៍នូវជំហានទី៣នេះ នោះពួកគេនឹងទទួលបានជោគជ័យដោយសារតែពួកគេមានការប្តេជ្ញាចិត្តពេញលេញសំរាប់ខ្លួនគេផ្ទាល់ ក្នុងការទទួលយកជំហានទី៣សំរាប់ជីវិតរបស់គេ។ ចំពោះអ្នកដែលទើបចូលរួមជាមួយកម្មវិធីអេអេ គេនឹងដឹងអំពីបញ្ហាជាច្រើនដែលអ្នកញៀនស្រានៅមិនទាន់បានដោះស្រាយ។ បន្ទាប់ពីគេបានឆ្លងកាត់នូវជំហានទី៣នេះហើយពួកគេនឹងអាចដោះស្រាយខ្លះបាន។ ជាដំបូងពួកគេគួតែព្រមបើកចិត្ត និងមានឆន្ទៈជាមុនសិន។ គេគឺជាមនុស្សតែម្នាក់គត់ដែលអាចធ្វើការសម្រេចចិត្តក្នុងការធ្វើសកម្មភាព ដែលត្រូវបានតំរូវឲ្យគាត់ធ្វើចំពោះជំហានដែលនៅសល់។ សម្រាប់ជំហានទាំង១២ គឺទាមទារឲ្យមានសកម្មភាពរហូតទៅដើម្បីឲ្យវាត្រូវគ្នា និងគោលការណ៍សំរាប់ការផ្លាស់ប្តូរនៅក្នុងកម្មវិធីរបស់អេអេ។ សរុបមកជំហានទាំងនេះវាស្របទៅនឹងព្រះហឫទ័យទ្រង់ ដើម្បីឲ្យពួកយើងរស់នៅដោយមានសុខភាពផ្លូវចិត្តល្អ ភាពប្រក្រតីផុតពីភាពស្រវឹងស្រា និងមានជីវិតមួយដែលមានតម្លៃសម្រាប់ខ្លួន និងអ្នកដទៃ។

នៅពេលដែលយើងព្យាយាមដើម្បីធ្វើឲ្យឆន្ទៈរបស់យើងស្របទៅនឹងឆន្ទៈរបស់ព្រះជាម្ចាស់ នោះយើងបានប្រើឆន្ទៈ និងការប្តេជ្ញាចិត្តរបស់ពួកយើងបានយ៉ាងត្រឹមត្រូវបំផុត។ អតីតកាលរបស់យើងបានបង្ហាញឲ្យយើងឃើញថា យើងបានប្រើប្រាស់កំលាំងកាយ ឆន្ទៈរបស់យើង ដើម្បីដោះស្រាយបញ្ហា ដោយខ្លួនឯង ដោយយើងមិនបានថ្វាយជីវិតរបស់យើងឲ្យស្ថិតក្នុងការថែរក្សារបស់ព្រះនោះទេ។ ជំហាន

ទាំង១២ របស់អេអេ វាអាចជាមធ្យោបាយមួយ ដែលនាំយើងឲ្យមានឆន្ទៈស្របទៅនឹងព្រះហឫទ័យរបស់ព្រះអង្គ។ ជំហានទី៣ជាជំហានដែលអាចជម្រុញយើងឲ្យវាសំរេចការទាំងនោះបាន។

ពួកយើងព្រមទទួលស្គាល់ថាកំលាំងនៃឆន្ទៈរបស់យើងមិនអាចជួយដោះស្រាយបាននូវបញ្ហារបស់យើងបានទេ ប៉ុន្តែពួកយើងអាចយកឆន្ទៈ និងការតាំងចិត្តនោះទៅអនុវត្តន៍នៅក្នុងជំហានទាំង១២នោះបាន ដើម្បីបំពេញនូវគោលការណ៍នៃកម្មវិធីសម្រាប់ជីវិតរបស់យើង។ បើសិនជាយើងព្រមតាម ហើយឥឡូវយើងអាចចាប់ផ្តើមជំហានទី៣បានហើយ។ នៅពេលដែលពួកយើងអន់ចិត្ត ខឹង ឬក៏មិនអាចសម្រេចចិត្តបាន ដូច្នេះសូមយើងបង្អង់ហើយនិយាយទៅកាន់ព្រះអង្គ។ ‘សូមទ្រង់ផ្តល់ឲ្យកូននូវភាពស្ងប់សុខ ដើម្បីឲ្យកូនអាចទទួលយកនូវអ្វីដែលកូនមិនអាចកែប្រែបាន សូមផ្តល់ចិត្តក្លាហានក្នុងការកែប្រែនូវអ្វីដែលកូនអាចធ្វើបាន សូមផ្តល់ប្រាជ្ញាឲ្យកូនចេះថ្លឹងថ្លែងនូវអ្វីដែលកូនអាចកែប្រែបាន និងអ្វីដែលកូនមិនអាចកែប្រែបាន’។